អេស៊ីលីដា
ACLEDA BANK

# របាយការណ៍ ប្រចាំ ត្រីមាសទី៤

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០)

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាលានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
|---|---|---|
| ទ្រព្យសកម្មសរុប | ២៦.៥០០.៧៩៣ | ២៥.១៦៣.៧៨៤ |
| បំណុលសរុប | ២២.០៩៣.២៥៨ | ២១.២៣៣.៦០៣ |
| មូលធនសរុប | ៤.៤០៧.៥៣៥ | ៣.៩៣០.១៨១ |
| **លទ្ធផលហិរញ្ញវត្ថុ (គិតជាលានរៀល)** | **ត្រីមាសទី៤ ឆ្នាំ២០២០** | **ត្រីមាសទី៤ ឆ្នាំ២០១៩** |
| ចំណូលសរុប | ៦២២.០៤៧ | ៥៦៦.១៨៣ |
| ចំណេញ/(ខាត) មុនបង់ពន្ធ | ២២២.១០៧ | ១៨០.២៨១ |
| ចំណេញ/(ខាត) សុទ្ធក្នុងការិយបរិច្ឆេទ | ១៧៥.២៦៩ | ១៤២.១០០ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ១៧៧.១៣៥ | ១៤១.៩៩៥ |
| **អនុបាតហិរញ្ញវត្ថុ (%)** | **ត្រីមាសទី៤ ឆ្នាំ២០២០** | **ឆ្នាំ២០១៩** |
| អនុបាតសាធនភាព | ២៥,១៦% | ២៦,៣១% |
| អនុបាតបំណុលធៀបនឹងមូលធន | ៥០១,២៦% | ៥៤០,២៧% |
| អនុបាតក្របខ័ណ្ឌសន្ទនីយភាព | ១៤៩,៣១% | ១៦៧,២៧% |
| អនុបាតឥណទានមិនដំណើរការ (*) | ២,៤០% | ១,២៤% |
| អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ | ៩៧,៧៣% | ៨៨,៨២% |
| **អនុបាតផលចំណេញ** | **ត្រីមាសទី៤ ឆ្នាំ២០២០** | **ត្រីមាសទី៤ ឆ្នាំ២០១៩** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA)(**) | ០,៦៧% | ០,៥៦% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE) (**) | ៤,០៧% | ៣,៦៧% |
| អនុបាតលទ្ធភាពសងការប្រាក់ (ដង) | ២,៤៤ | ២,១៣ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ៤០៨,៩៣ | ៣៣១,១៣ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត | គ្មាន | គ្មាន |

(*) ឥណទានមិនដំណើរការ = ឥណទាននៅដំណាក់កាលទី៣

(**) អនុបាតទាំងនេះមិនមែនជាអនុបាតប្រចាំឆ្នាំនោះទេ ហើយត្រូវបានគណនាដោយប្រើតួលេខលទ្ធផលលម្អិតសរុប រយៈពេល ៣ខែ ចាប់ពីថ្ងៃទី០១ ខែតុលា ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២០។

## ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប







អនុបាតហិរញ្ញវត្ថុ (%)
៦០០%
៥០០%
៤០០%
៣០០%
២០០%
១០០%
០%
២៥,១៦%
២៦,៣១%
៥០១,២៦%
៥៤០,២៧%
១៤៩,៣១%
១៦៧,២៧%
២,៤០%
១,២៤%
៩៧,៧៣%
៨៨,៨២%
អនុបាតសាធនភាព
អនុបាតបំណុលធៀបនឹងមូលធន
អនុបាតគ្របខណ្ឌសទ្ធីយភាព
អនុបាតឥណទានមិនដំណើរការ (*)
អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ
ត្រីមាសទី៤ ឆ្នាំ២០២០
ឆ្នាំ២០១៩


អនុបាតចំណេញភាព
០,៦៧%
០,៥៦%
៤,០៧%
៣,៦៧%
អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA)
អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE)
ត្រីមាសទី៤ ឆ្នាំ២០២០
ត្រីមាសទី៤ ឆ្នាំ២០១៩

# សមាសភាពក្រុមប្រឹក្សាភិបាល



លោក ឆាយ សឿន
*ប្រធានក្រុមប្រឹក្សាភិបាល*



បណ្ឌិត អ៊ិន ចាន់នី
*អភិបាលប្រតិបត្តិ*



លោក រ័ត្ន ឃូម៉េង
*អភិបាលប្រតិបត្តិ*



លោក Stéphane Mangiavacca
*អភិបាលមិនប្រតិបត្តិ*



លោក Kenichiro Mori
*អភិបាលមិនប្រតិបត្តិ*



លោកស្រី Mirjam Janssen
*អភិបាលមិនប្រតិបត្តិ*



បណ្ឌិត Pieter Kooi
*អភិបាលឯករាជ្យ*



លោក Ian Samuel Lydall
*អភិបាលឯករាជ្យ*



លោក វ៉ាន់ ស៊ូអៀង
*អភិបាលឯករាជ្យ*

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

តាងនាមឲ្យធនាគារ អេស៊ីលីដា ភីអិលស៊ី (“ធនាគារ’) និងក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ សូមធ្វើការបង្ហាញជូន អំពីរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី៤ ឆ្នាំ២០២០ របស់ធនាគារ សម្រាប់រយៈពេល គិតចាប់ពីថ្ងៃទី ០១ ខែតុលា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

ដោយដំណើរការអាជីវកម្មរបស់ធនាគារនៅឆ្នាំ២០២០ ក្រោមស្ថានភាពដ៏លំបាកនៃការរាតត្បាតជាសកល នៃជំងឺកូវីដ-១៩ ធនាគារ បានពង្រីកបណ្តាញស្វ័យប្រតិបត្តិការ អភិវឌ្ឍសេវាធនាគារឌីជីថលឲ្យកាន់តែងាយស្រួល រហ័សទាន់ចិត្ត និងមានសុវត្ថិភាពខ្ពស់។ មិនតែប៉ុណ្ណោះ ធនាគារតែងតែខិតខំធ្វើឲ្យប្រតិបត្តិការរបស់ខ្លួនកាន់តែប្រសើរឡើង ដោយបន្តធ្វើទំនើបកម្ម និងនវានុវត្តន៍ផលិតផល-សេវាកម្ម និងពង្រឹងគុណភាពការបម្រើសេវាកម្មនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ ស្របតាមការអនុវត្តនេះ ធនាគារសម្រេចបាននូវលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ប្រាក់បញ្ញើសរុបបានកើនឡើងចំនួន ២៤៣,៤០ លានដុល្លារអាមេរិក ហើយសមតុល្យឥណទានសរុបបានកើនឡើងចំនួន ៦២៧,១៨ លានដុល្លារអាមេរិក បើធៀបនឹងដំណាច់ឆ្នាំ២០១៩។

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២០ នេះ បើធៀបនឹងត្រីមាសទី៤ដូចគ្នា ក្នុងឆ្នាំ២០១៩ ធនាគារ អេស៊ីលីដា ភីអិលស៊ី ទទួលបានប្រាក់ចំណេញសុទ្ធចំនួន ៤៣,១៣ លានដុល្លារអាមេរិក ដោយកើនឡើង ២៣,៣១% ស្មើនឹង ៨,១៥ លានដុល្លារអាមេរិក ។ ធនាគារទទួលបានអនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យមចំនួន ០,៦៧% ដោយកើនឡើងចំនួន ០,១១% និងទទួលបានអនុបាតចំណេញធៀបនឹងមូលធនមធ្យមចំនួន ៤,០៧% ដោយកើនឡើងចំនួន ០,៤០%។

ទោះបីជាការរីករាលដាលនៃជំងឺឆ្លងជាសកលបានប៉ះពាល់ជាអវិជ្ជមានគ្រប់វិស័យនៅក្នុងប្រទេសក៏ដោយ ក៏ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅតែទទួលបានការដំឡើងចំណាត់ថ្នាក់ Stand-Alone Credit Profile (SACP) ពីកម្រិត ‘bb-’ ទៅកម្រិត ‘bb’ ពីភ្នាក់ងារវាយតម្លៃអន្តរជាតិ Standard & Poor's (S&P) Global Ratings។ ការទទួលបាននេះ គឺដោយមូលហេតុចម្បងៗដូចជា ធនាគាររក្សាបាននូវទ្រព្យសកម្មចម្រុះ ការគ្រប់គ្រងដោយការប្រុងប្រយ័ត្ន ការគិតគូរនូវរាល់ហានិភ័យពាក់ព័ន្ធទាំងអស់ សម្រាប់ជាមូលដ្ឋាននៃការលូតលាស់ និងមានមូលធនភាវូបនីយកម្មរឹងមាំ។

ក្នុងបរិការណ៍ដែលថ្នាំបង្ការមានប្រសិទ្ធភាព អាចទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩បានក្នុងឆមាសទី១ នៃឆ្នាំ២០២១ ទស្សនវិស័យសម្រាប់ឆ្នាំ២០២១ គឺមានភាពវិជ្ជមាន ដោយសេដ្ឋកិច្ចកម្ពុជារំពឹងថានឹងអាចងើបឡើងវិញក្នុងរង្វង់ ៣,៥% បើយោងតាមរបាយការណ៍ប្រចាំឆ្នាំ២០២០ របស់ធនាគារជាតិ នៃ កម្ពុជា។ ទស្សនវិស័យវិជ្ជមាននៃសេដ្ឋកិច្ចកម្ពុជា បានបង្កើតឱកាសសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ជាពិសេសដល់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាតួអង្គដ៏សំខាន់នៅក្នុងវិស័យនេះ អាចពង្រីកនូវវិសាលភាពប្រតិបត្តិការរបស់ខ្លួនក្នុងការគាំទ្រជាឆ្អឹងខ្នងសេដ្ឋកិច្ច។

យើងខ្ញុំសូមថ្លែងអំណរគុណ និងសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះភាគហ៊ុនិក អតិថិជន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ដែលបានបន្តការជ្រោមជ្រែង និងគាំទ្រដល់ធនាគារ។ អ្នកទាំងអស់គ្នាគឺជាចំណែកនៃភាពជោគជ័យរបស់ធនាគារ បើគ្មានការគាំទ្រឥតឈប់ឈររបស់លោកអ្នកនោះទេ ធនាគារក៏មិនអាចសម្រេចតាមផែនការដ៏ត្រចះត្រចង់នេះដែរ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១
ហត្ថលេខា និងត្រា

ធនាគារ អេស៊ីលីដា ភីអិលស៊ី
ACLEDA BANK PLC.

**ឆាយ សឿន**

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ..... i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ..... ii

សមាសភាពក្រុមប្រឹក្សាភិបាល ..... iv

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ..... v

**ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១**

**ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១**

**ខ- លក្ខណៈនៃធុរកិច្ច ..... ១**

**គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១**

**ផ្នែកទី ២-ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ..... ២**

**ក-លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ..... ២**

**ខ-រចនាសម្ព័ន្ធចំណូល ..... ៤**

**ផ្នែកទី ៣-របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ ..... ៤**

**ផ្នែកទី ៤-ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ..... ៥**

**ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ..... ៥**

**ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ..... ៧**

**គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ..... ៨**

**ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ..... ៩**

**ង-ផលប៉ះពាល់នៃអតិផរណា ..... ៩**

**ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ..... ៩**

**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១១**

## ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

### ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ អេស៊ីលីដា ភីអិលស៊ី** |
| ជាអក្សរឡាតាំង | **ACLEDA Bank Plc.** |
| លេខកូដស្តង់ដារ | KH១០០០១០០០០៣ |
| ទីស្នាក់ការ | អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (០)២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩ |
| លេខទូរសារ | +៨៥៥ (០)២៣ ៤៣០ ៥៥៥ |
| គេហទំព័រ | www.acledabank.com.kh |
| អ៊ីម៉ែល | acledabank@acledabank.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៣០៧៧ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ០៦ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ ចេញដោយ ធនាគារជាតិ នៃ កម្ពុជា |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | លេខ០៥៣/២០គ.ម.ក./ស.ស.រ. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ចេញដោយគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | **បណ្ឌិត អ៊ិន ចាន់នី** |

### ខ- លក្ខណៈនៃធុរកិច្ច

ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាធនាគារពាណិជ្ជដែលមានសាខា និងបណ្តាញការិយាល័យធំជាងគេបង្អស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារបានចុះបញ្ជីនៅក្នុង ផ.ម.ក. ចាប់តាំងពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។ បច្ចុប្បន្ននេះធនាគារមានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន៤ រួមមាន៖ ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យួរីធី ភីអិលស៊ី វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា និងស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ព្រមទាំងមានការិយាល័យតំណាងចំនួន១ នៅប្រទេសមីយ៉ាន់ម៉ាផងដែរ។

### គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

- ធនាគារ អេស៊ីលីដា ភីអិលស៊ី បានបរិច្ចាគថវិកាចំនួន ២៥ម៉ឺនដុល្លារអាមេរិក ដើម្បីជួយសង្គ្រោះប្រជាពលរដ្ឋដែលរងគ្រោះដោយសារទឹកជំនន់ដែលកំពុងកើតមាននៅក្នុងប្រទេស និងជាការព្រួយបារម្ភរបស់ប្រជាជនទូទាំងប្រទេសផងដែរ។

- នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញរបស់ខ្លួន ហើយនេះគឺជាលើកទី១ ដែលធនាគារបានរៀបចំមហាសន្និបាតដោយមានការចូលរួមពីភាគហ៊ុនិកសាធារណៈ។

- ធនាគារ បានបរិច្ចាគថវិកាចំនួន ១.០០០.០០០.០០០ (មួយពាន់លានរៀល) ចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការទិញវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដើម្បីលើកកម្ពស់សុខុមាលភាពសាធារណៈ។

- ធនាគារ អេស៊ីលីដា បានទទួលការដំឡើងចំណាត់ថ្នាក់ Stand-Alone Credit Profile (SACP) ពីកម្រិត 'bb-' ទៅកម្រិត 'bb' ពីភ្នាក់ងារវាយតម្លៃអន្តរជាតិ Standard & Poor's (S&P) Global Ratings។ ទស្សនវិស័យស្ថិរភាពដែលបង្ហាញនៅក្នុងចំណាត់ថ្នាក់នេះ ឆ្លុះបញ្ចាំងពីភាពរឹងមាំនៃហិរញ្ញវត្ថុជាមួយនឹងទ្រនាប់ដើមទុនគ្រប់គ្រាន់ ដើម្បីស្ថិរភាពនៃដំណើរការអាជីវកម្ម។

- ធនាគារបានប្រារព្ធពិធីដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៃនិមិត្តសញ្ញាថ្មីរបស់ខ្លួន ដោយរក្សានូវនិមិត្តរូប អត្តសញ្ញាណ និងអត្ថន័យដែលធនាគារបានកសាងជាង២៩ឆ្នាំកន្លងមក។ ស្លាកសញ្ញាថ្មីរបស់ធនាគារ ជា "និមិត្តរូបបក្សីស្ទួគិ" ឈរនៅចំកណ្តាលរង្វង់មូលពណ៌ខៀវទឹកប៊ិក ដែលបង្ហាញពីភាពរឹងមាំ និងវឌ្ឍនភាពប្រកបដោយចីរភាព។

- បន្ថែមពីការដាក់ឱ្យប្រើប្រាស់នូវស្លាកសញ្ញាថ្មី កម្មវិធីទូរស័ព្ទចល័តរបស់ធនាគារក៏បានកែប្រែរូបរាងថ្មី និងប្តូរឈ្មោះពីអេស៊ីលីដាយូនីធីទាន់ចិត្ត ទៅ **អេស៊ីលីដាម៉ូបាល** (**ACLEDA mobile**)។ រូបរាងថ្មីរបស់ **អេស៊ីលីដាម៉ូបាល** (**ACLEDA mobile**) ត្រូវបានរចនាឡើងដោយអ្នកជំនាញដែលមានបទពិសោធន៍ខាងបញ្ចូលបច្ចេកវិទ្យាចុងក្រោយទៅក្នុងកម្មវិធី (app) ហើយវាត្រូវបានបំពាក់ដោយប្រព័ន្ធសុវត្ថិភាពអាយអេសអូ (ISO) និងឧស្សាហកម្មប័ណ្ណទូទាត់ (PCI) លំដាប់ថ្នាក់ពិភពលោកដែលធានាបាននូវកម្រិតសុវត្ថិភាពខ្ពស់បំផុត។ ជាមួយនឹងរូបរាងថ្មីរបស់ **អេស៊ីលីដាម៉ូបាល** (**ACLEDA mobile**) គឺដើម្បីជួយឱ្យសេវាទូរស័ព្ទចល័តរបស់ធនាគារអាចឆ្លើយតបទៅនឹងភាពរីកចម្រើននៃបច្ចេកវិទ្យារបស់ពិភពលោក និងវឌ្ឍនភាពរបស់ធនាគារក្នុងយុគសម័យឌីជីថល។

# ផ្នែកទី ២-ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក-លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

- **ប្រតិបត្តិការក្នុងវិស័យធនាគារ**

  មានធនាគារពាណិជ្ជចំនួន៥៣ (ធនាគារក្នុងស្រុកចំនួន២២ បុត្រសម្ព័ន្ធធនាគារបរទេសចំនួន១៧ និងសាខាធនាគារបរទេសចំនួន១៤) ធនាគារឯកទេសចំនួន១៤ (ធនាគារក្នុងស្រុកចំនួន០៦ និងធនាគារបរទេសចំនួន០៨) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៨១ (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន០៦ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើចំនួន៧៥) ក្រុមហ៊ុនភតិសន្យាចំនួន១៥ ការិយាល័យតំណាងធនាគារបរទេសចំនួន០៦ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន២៤ និងគ្រឹះស្ថានឥណទានជនបទចំនួន២៤៦។(Source: NBC Report, CMA Report, and Actually Updated)

- **ប្រតិបត្តិការអាជីវកម្ម និងចំណែកទីផ្សាររបស់ធនាគារ អេស៊ីលីដា នៅក្នុងវិស័យធនាគារ:**

  ធនាគារ អេស៊ីលីដា ភីអិលស៊ី មានចំណែកទីផ្សារ ១៤,៩៨% និង ១៣,៨៩% រៀងគ្នាសម្រាប់ប្រាក់បញ្ញើ និងឥណទាន គិតត្រឹមដំណាច់ខែវិច្ឆិកា ឆ្នាំ២០២០។

  គិតនៅត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២០ ធនាគារ អេស៊ីលីដា និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនទទួលបានលទ្ធផលល្អទាំងការលក់ និងចំណូល។ លទ្ធផលសំខាន់ៗសម្រេចបានគិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២០ មានដូចខាងក្រោម៖

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | |
|---|---|---|
| | ត្រីមាសទី៤ ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
| **សេវាឥណទាន** | | |
| ចំនួនឥណទានសកម្ម | ៥៥៥.៣២៣ | ៥៣៦.៨៩១ |
| សមតុល្យឥណទានសរុប (លានរៀល) | ១៨.២២៩.៣៧២ | ១៥.៨០៨.៨១៤ |

| | | |
|---|---|---|
| **សេវាបញ្ញើ-សន្សំ** | | |
| ចំនួនគណនីសរុប | ២.៨៩៤.៩០៧ | ២.៦២០.៧៧៨ |
| ចំនួនទឹកប្រាក់សរុប (លានរៀល) | ១៨.៦៥២.៦៩០ | ១៧.៧៩៩.១៨៤ |
| **សេវាធនាគារអេឡិចត្រូនិក** | | |
| **ប័ណ្ណអេធីអឹម អេស៊ីលីដា** | | |
| ចំនួនប័ណ្ណបោះផ្សាយសរុប | ១.៣៩៦.៧៧៨ | ១.២៧៧.៧២៥ |
| ចំនួនប្រតិបត្តិការសរុប | ១៩.៧៦៨.២២៣ | ២០.៤០៣.២០០ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៣.៧៧៥.៩១៨ | ១២.៥៤៨.០៦៦ |
| **សេវាធនាគារចល័ត** | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ១.៧៨២.៨១៤ | ១.២៧៦.៥២៨ |
| ចំនួនប្រតិបត្តិការសរុប | ៤៨.៧៤៩.៥៩៩ | ២៨.២៦៤.៩៧២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៥៩.២១១.២៧៩ | ៣៧.៣០៣.១៣៧ |
| **សេវាអេស៊ីលីដាអ៊ីនធើណែត** | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ១១.៦៧៩ | ១១.៣៣១ |
| ចំនួនប្រតិបត្តិការសរុប | ៨៨៦.៩៩០ | ៥១០.២៩៧ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១១.២៨៥.៩៤៨ | ៥.២៣៥.៦១៦ |
| **សេវាអេស៊ីលីដាអ៊ីខុមមើស** | | |
| ចំនួនដៃគូអាជីវកម្មសរុប | ៥១ | ៤៨ |
| ចំនួនប្រតិបត្តិការសរុប | ៤៤៧.៩២៩ | ៤៦៧.៦៦៨ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៣៦០.០០០ | ២១៣.២៦២ |
| **ម៉ាស៊ីនអេធីអឹម អេស៊ីលីដា** | | |
| ចំនួនម៉ាស៊ីនសរុប | ៧៩០ | ៦៨៣ |
| ចំនួនប្រតិបត្តិការសរុប | ២៦.៥៧៤.៦៧៨ | ២៤.១៨១.២៣១ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ២០.១៩៨.៧២៤ | ១៥.៩២៩.១៩៧ |
| **ម៉ាស៊ីនឆូតកាត អេស៊ីលីដា** | | |
| ចំនួនម៉ាស៊ីនឆូតកាតសរុប | ៤.២៨៧ | ៤.២៨៩ |

| | | |
|---|---|---|
| ចំនួនប្រតិបត្តិការសរុប | ២.៤៥៧.៦២៦ | ២.៤១២.៩៣៨ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៦៥៧.៥០៦ | ៨៤៩.៣៩២ |
| **កូដ QR នៅតាមហាងទំនិញនានា** | | |
| ចំនួនពាណិជ្ជករបំពាក់កូដ QR | ៦៣.៧១៤ | ៣០.៩៤៩ |
| ចំនួនប្រតិបត្តិការសរុប | ១.៨៤២.៩១៣ | ៧៣៥.៣១២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៨៦.៦៩១ | ៩០.៨៨៦ |
| **បណ្ដាញប្រតិបត្តិការ និង បុគ្គលិក** | | |
| **ធនាគារ អេស៊ីលីដា ភីអិលស៊ី** | | |
| ចំនួនការិយាល័យសរុប | ២៦៣ | ២៦២ |
| ចំនួនបុគ្គលិកសរុប | ១២.០១៣ | ១១.៩៩៧ |
| **ក្រុមហ៊ុនបុត្រសម្ព័ន្ធ (ក្នុង និង ក្រៅប្រទេស)** | | |
| ចំនួនការិយាល័យសរុប | ៥៦ | ៥៣ |
| ចំនួនបុគ្គលិកសរុប | ១.៦៩១ | ១.៦៥៨ |

## ខ-រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២០ | | ត្រីមាសទី៤ ឆ្នាំ២០១៩ | |
|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៥៤៨.០៤៥ | ៨៨,១០% | ៤៩៧.០៤២ | ៨៧,៧៩% |
| ២ | ចំណូលកម្រៃ និងជើងសា | ៤៨.០៩៧ | ៧,៧៣% | ៤៩.១៧៧ | ៨,៦៩% |
| ៣ | ចំណូលផ្សេងៗ | ២៥.៩០៥ | ៤,១៦% | ១៩.៩៦៤ | ៣,៥៣% |
| **ចំណូលសរុប** | | **៦២២.០៤៧** | **១០០%** | **៥៦៦.១៨៣** | **១០០%** |

# ផ្នែកទី ៣-របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនកររឯករាជ្យ

សូមពិនិត្យមើលឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ
របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានត្រួតពិនិត្យឡើងវិញដោយសវនកររឯករាជ្យ

## ផ្នែកទី ៤-ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះផ្តោតសំខាន់លើលទ្ធផលប្រតិបត្តិការ និងលទ្ធផលហិរញ្ញវត្ថុដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេលគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដែលត្រូវបានត្រួតពិនិត្យដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុចន្លោះពេលត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា(ស.រ.ហ.អ.ក)។ មានតែសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញរបស់ធនាគារប៉ុណ្ណោះត្រូវបានយកមកធ្វើការពិភាក្សា និងវិភាគ។

## ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១-ការវិភាគចំណូល

ធនាគារ អេស៊ីលីដា ភីអិលស៊ី មានប្រភពចំណូលធំៗចំនួនបីគឺ ចំណូលការប្រាក់ ចំណូលកម្រៃនិងជើងសា និងចំណូលផ្សេងៗ។

- ចំណូលការប្រាក់៖ រួមមានចំណូលការប្រាក់ពីឥណទាននិងបុរេប្រទាន ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងការវិនិយោគហិរញ្ញវត្ថុ។
- ចំណូលកម្រៃ និងជើងសា៖ រួមមានកម្រៃជើងសា កម្រៃជើងសាបានពីភ្នាក់ងារធានារ៉ាប់រង កម្រៃពីម៉ាស៊ីនអេធីអឹម កម្រៃពីការសងឥណទានមុនកាលកំណត់ កម្រៃពីសេវាប្រាក់បញ្ញើ កម្រៃពីសេវាធានា និងកម្រៃពីការបណ្តុះបណ្តាល។
- ចំណូលផ្សេងៗ៖ រួមមានចំណេញពីការប្តូររូបិយប័ណ្ណ ចំណេញពីការលក់ទ្រព្យនិងបរិក្ខារ ភាគលាភលើការវិនិយោគហិរញ្ញវត្ថុ និងចំណូលផ្សេងៗ។

### ២-ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល (គិតជាលានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២០ | | ត្រីមាសទី៤ ឆ្នាំ២០១៩ | |
|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៥៤៨.០៤៥ | ៨៨,១០% | ៤៩៧.០៤២ | ៨៧,៧៩% |
| ២ | ចំណូលកម្រៃ និងជើងសា | ៤៨.០៩៧ | ៧,៧៣% | ៤៩.១៧៧ | ៨,៦៩% |
| ៣ | ចំណូលផ្សេងៗ | ២៥.៩០៥ | ៤,១៦% | ១៩.៩៦៤ | ៣,៥៣% |
| **ចំណូលសរុប** | | **៦២២.០៤៧** | **១០០%** | **៥៦៦.១៨៣** | **១០០%** |

ចំណូលសរុបចំនួន ៦២២.០៤៧ លានរៀល ក្នុងត្រីមាសទី៤ ឆ្នាំ២០២០ ភាគច្រើនបានមកពីចំណូលការប្រាក់ដែលមានចំណែក ៨៨,១០% នៃចំណូលសរុប និងចំណូលសរុបបានកើនឡើងចំនួន ៥៥.៨៦៤ លានរៀល ឬ ៩,៨៧% បើប្រៀបធៀបទៅនឹងចំណូលសរុបក្នុងត្រីមាសទី៤ ឆ្នាំ២០១៩។

### ៣-ការវិភាគគម្លាតចំណេញដុល

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី បានរៀបចំក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីគម្លាតចំណេញដុលទេ។ ចំណូលការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុបដកនឹងចំណាយការប្រាក់សរុប នឹងត្រូវយកមកបង្ហាញនៅក្នុងការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ ដូចខាងក្រោម។

## ៤-ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២០ | ត្រីមាសទី៤ ឆ្នាំ២០១៩ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ចំណូលការប្រាក់ | ៥៤៨.០៤៥ | ៤៩៧.០៤២ | ៥១.០០៣ | ១០,២៦% |
| ចំណាយការប្រាក់ | (១៥៤.៥៦៧) | (១៥៨.៩១៤) | ៤.៣៤៧ | -២,៧៤% |
| **ចំណូលការប្រាក់សុទ្ធ** | **៣៩៣.៤៧៨** | **៣៣៨.១២៨** | **៥៥.៣៥០** | **១៦,៣៧%** |
| ចំណូលកម្រៃ និងជើងសា | ៤៨.០៩៧ | ៤៩.១៧៧ | (១.០៨០) | -២,២០% |
| ចំណាយកម្រៃ និងជើងសា | (២.២៤៥) | (១.៦៥៤) | (៥៩១) | ៣៥,៧៣% |
| **ចំណូលកម្រៃ និងជើងសាសុទ្ធ** | **៤៥.៨៥២** | **៤៧.៥២៣** | **(១.៦៧១)** | **-៣,៥២%** |
| សំវិធានធនសម្រាប់ការខាតបង់ឱនភាពនៃតម្លៃរបស់ឥណទាននិងបុរេប្រទាន ប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងគណនីត្រូវទទួលផ្សេងៗ | (៤.២៤៩) | (១០.២៨៧) | ៦.០៣៨ | -៥៨,៧០% |
| សំវិធានធនសម្រាប់ការខាតបង់ឱនភាពនៃតម្លៃរបស់កិច្ចសន្យាក្រៅតារាងតុល្យការ | ៨០ | (៤៤៨) | ៥២៨ | -១១៧,៨៦% |
| **ឱនភាពនៃតម្លៃខាតបង់សុទ្ធ** | **(៤.១៦៩)** | **(១០.៧៣៦)** | **៦.៥៦៧** | **-៦១,១៧%** |
| **ចំណូលសុទ្ធបន្ទាប់ពីសំវិធានធនសម្រាប់ឱនភាពនៃតម្លៃ** | **៤៣៥.១៦១** | **៣៧៤.៩១៦** | **៦០.២៤៥** | **១៦,០៧%** |
| ចំណូលផ្សេងៗ | ២៥.៩០៥ | ១៩.៩៦៤ | ៥.៩៤១ | ២៩,៧៦% |
| ចំណាយទូទៅ និងរដ្ឋបាល | (២៣៨.៩៥៩) | (២១៤.៥៩៩) | (២៤.៣៦០) | ១១,៣៥% |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **២២២.១០៧** | **១៨០.២៨១** | **៤១.៨២៦** | **២៣,២០%** |

នៅត្រីមាសទី៤ ឆ្នាំ២០២០ ប្រាក់ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញបានកើនឡើង ៤១.៨២៦ លានរៀល ឬ ២៣,២០% បើប្រៀបធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៩។ ចំណូលការប្រាក់បានកើនឡើង ១០,២៦% ខណៈពេលដែលចំណាយការប្រាក់បានថយចុះ ២,៧៤% ដែលនាំឱ្យមានការកើនឡើងនូវចំណូលការប្រាក់សុទ្ធ ១៦,៣៧%។

## ៥-ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២០ | ត្រីមាសទី៤ ឆ្នាំ២០១៩ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **២២២.១០៧** | **១៨០.២៨១** | **៤១.៨២៦** | **២៣,២០%** |
| ចំណាយពន្ធលើប្រាក់ចំណេញ | (៤៦.៨៣៨) | (៣៨.១៨១) | (៨.៦៥៧) | ២២,៦៧% |
| **ប្រាក់ចំណេញសម្រាប់ការិយបរិច្ឆេទ** | **១៧៥.២៦៩** | **១៤២.១០០** | **៣៣.១៦៩** | **២៣,៣៤%** |

ប្រាក់ចំណេញសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២០នេះ ខ្ពស់ជាងត្រីមាសទី៤ ឆ្នាំ២០១៩ ចំនួន ៣៣.១៦៩ លានរៀល ឬ ២៣,៣៤%។ ការកើនឡើងនេះ ភាគច្រើនបណ្ដាលមកពីការកើនឡើងនូវចំណូលការប្រាក់សុទ្ធចំនួន ១៦,៣៧% ស្មើនឹង ៥៥.៣៥០ លានរៀល ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៩។

## ៦-ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| លទ្ធផលលម្អិតសរុប (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២០ | ត្រីមាសទី៤ ឆ្នាំ២០១៩ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ប្រាក់ចំណេញសម្រាប់ការិយបរិច្ឆេទ** | **១៧៥.២៦៩** | **១៤២.១០០** | **៣៣.១៦៩** | **២៣,៣៤%** |
| **លទ្ធផលលម្អិតផ្សេងៗ៖**<br>**ធាតុដែលនឹងមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញទៅចំណេញ ឬខាត៖**<br>ការវាស់វែងឡើងវិញនៃកាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | ១.៨៦៦ | (១០៥) | ១.៩៧១ | ១.៨៧៧,១៤% |
| **ធាតុដែលត្រូវ ឬអាចត្រូវបានចាត់ថ្នាក់ឡើងវិញនៅការិយបរិច្ឆេទបន្ទាប់ទៅចំណេញ ឬខាត៖**<br>លម្អៀងពីការប្ដូររូបិយប័ណ្ណ | - | - | - | - |
| **លទ្ធផលលម្អិតផ្សេងៗសម្រាប់ការិយបរិច្ឆេទសរុប** | **១៧៧.១៣៥** | **១៤១.៩៩៥** | **៣៥.១៤០** | **២៤,៧៥%** |

## ៧-ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ មានឥទ្ធិពលគួរឱ្យកត់សម្គាល់លើស្ទើរតែគ្រប់វិស័យទាំងអស់ រួមទាំងធនាគារ និងហិរញ្ញវត្ថុផងដែរ។ ឧស្សាហកម្មទេសចរណ៍រួមទាំងសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងរបស់របរទាក់ទងនឹងម្ហូបអាហារបានរងផលប៉ះពាល់យ៉ាងខ្លាំង។ ទោះបីជាគ្រប់សហគ្រាសទទួលរងនូវផលប៉ះពាល់ក៏ដោយ ប៉ុន្តែធនាគារ អេស៊ីលីដា បានបង្កើតឲ្យមានភាពវិជ្ជមានដោយបង្កើតឲ្យមានកម្មវិធីសំណើសុំឥណទានដែលមានភាពសាមញ្ញ និងងាយស្រួលប្រើប្រាស់ដោយមធ្យោបាយឌីជីថល តាមរយៈកម្មវិធី '**អេស៊ីលីដាម៉ូបាល**' ហើយវាក៏អាចប្រើជាមួយគណនីប្រាក់បញ្ញើ-សន្សំ (សំចៃ ចរន្ត និងមានកាលកំណត់) ផងដែរ រួមជាមួយអត្រាការប្រាក់ដែលមានភាពបត់បែន។

# ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

## ១-ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ធនាគារ អេស៊ីលីដា ទទួលបានជោគជ័យនៅលើទីផ្សារដែលនាំមកនូវផលចំណេញអាស្រ័យដោយកត្តាពីរគឺ៖

- កំណើនសំពៀតឥណទាន ដោយសារតម្រូវការខ្ពស់នៅលើទីផ្សារលើផលិតផលឥណទានរបស់ធនាគារ ជាពិសេសវិស័យ SME។
- កំណើនប្រាក់បញ្ញើ-សន្សំ របស់ធនាគារ រួមជាមួយផលិតផល និងសេវាកម្មផ្សេងទៀត។

កត្តាទាំងពីរនេះត្រូវបានផ្សារភ្ជាប់ជាមួយនឹងការអភិវឌ្ឍឥតឈប់ឈរនៃប្រព័ន្ធឌីជីថលរបស់ធនាគារ ដែលផ្ដល់ជូនអតិថិជននូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងទាន់សម័យ។

ការបង្កើនភាពងាយស្រួលដល់អតិថិជន និងពង្រឹងប្រព័ន្ធសុវត្ថិភាពអ៊ិនធើណែត គឺជាចំណុចដែលធនាគារ អេស៊ីលីដា ផ្តោតការយកចិត្តទុកដាក់បំផុត។ ដើម្បីសម្រេចនូវវឌ្ឍនភាពគោលដៅដ៏រឹងមាំទាំងនេះ ធនាគារនឹងបន្តលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមរយៈការវិនិយោគលើបច្ចេកវិទ្យាទំនើបចុងក្រោយ ពង្រឹងសមត្ថភាពធនធានមនុស្ស ព្រមទាំងពង្រីកនិងកែលម្អដំណើរការអាជីវកម្ម។ ជាយុទ្ធសាស្ត្រ ធនាគារកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ដែលអាចឱ្យដៃគូទាំងក្នុង និងក្រៅប្រទេសអាចភ្ជាប់ប្រព័ន្ធនេះដើម្បីបម្រើអតិថិជនទៅវិញទៅមក និងឆ្លងព្រំដែន។ ប្រព័ន្ធនេះមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់អតិថិជនដ៏ឆ្លាតវៃរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដៃគូអាជីវកម្មរបស់យើងផងដែរ។ យើងខ្ញុំទទួលស្គាល់ថាអតិថិជន និងដៃគូអាជីវកម្មទាំងអស់គឺជាបណ្តាញតភ្ជាប់ដ៏មានសារសំខាន់សម្រាប់ពង្រីកសេវាកម្មរបស់ធនាគារ និងរីកចម្រើនជាមួយគ្នា។

**អេស៊ីលីដាម៉ូបាល** បានកែលម្អយ៉ាងទូលំទូលាយ និងផ្លាស់ប្តូររូបរាងថ្មី កាន់តែទំនើប ងាយស្រួល និងមានសុវត្ថិភាពខ្ពស់ ជាមួយនឹងមុខងារពិសេសៗជាច្រើន ។ ឥឡូវនេះ អតិថិជនទាំងអស់អាចប្រតិបត្តិការប្រាក់បញ្ញើ-សន្សំ (សំចៃ ចរន្ត និងមានកាលកំណត់) តាមរយៈ **អេស៊ីលីដាម៉ូបាល** បានភ្លាមៗ ថែមទាំងទទួលបានការប្រាក់ខ្ពស់ទៀតផង។ លោកអ្នកក៏អាចដាក់ប្រាក់បញ្ញើមានកាលកំណត់ដោយខ្លួនឯងបានយ៉ាងងាយស្រួល ជាមួយម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់ផងដែរ។

ធនាគារក៏បាន និងកំពុងបន្តវិនិយោគក្នុងការពង្រីកទីតាំងស្វ័យសេវាធនាគារ ដោយធ្វើការដំឡើងបន្ថែមនូវម៉ាស៊ីនអេធីអឹម ម៉ាស៊ីនដក-ដាក់ប្រាក់ ម៉ាស៊ីនឆូតកាត និងការពង្រីកបណ្តាញទូទាត់តាម QR របស់ខ្លួន។

ដើម្បីគាំទ្រដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (ក្នុងអំឡុងពេលនៃការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩) ឱ្យមានសន្ទនីយភាពបន្ថែមទៀតដើម្បីឆ្លើយតបទៅនឹងតម្រូវការទុនរបស់ខ្លួន ធនាគារជាតិ នៃ កម្ពុជាបានបន្ធូរបន្ថយអនុបាតមួយចំនួនដូចជា៖ សាធនភាពទ្រនាប់ដើមទុន ប្រាក់បម្រុងកាតព្វកិច្ច។ល។ ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកាត់បន្ថយពន្ធកាត់ទុកលើការប្រាក់កម្ចី ក៏ដូចជាបង្កើតសន្ទនីយភាពបន្ថែមទៀតនៅលើទីផ្សារដែលមានថ្លៃដើមទាប។ កត្តាទាំងនេះបានផ្តល់ឱកាសសម្រាប់ការប្រកួតប្រជែងថ្លៃដែលអាចប៉ះពាល់ដល់ចំណូលរបស់ធនាគារក្នុងរយៈពេលខ្លី ប៉ុន្តែវានឹងជួយឱ្យមានភាពរឹងមាំសម្រាប់រយៈពេលវែង។

## ២-ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ធនាគារ អេស៊ីលីដា ភីអិលស៊ី ប្រតិបត្តិការក្នុងវិស័យសេវាកម្ម ដែលការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនអាចអនុវត្តបានចំពោះធនាគារឡើយ។

## ៣-ការវិភាគលើពន្ធ

ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃប្រទេសនីមួយៗ ដូច្នេះធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធមានកាតព្វកិច្ចបង់ពន្ធតាមការកំណត់របស់អាជ្ញាធរពន្ធដារនីមួយៗ។

ការបង់ពន្ធជូនអគ្គនាយកដ្ឋានពន្ធដារមិនត្រឹមតែជាកាតព្វកិច្ច និងការទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ **"មាស"** ពីអគ្គនាយកដ្ឋានពន្ធដារសម្រាប់ឆ្នាំជាប់ពន្ធ ២០២០ ដល់ ២០២១ ប៉ុណ្ណោះទេ ប៉ុន្តែជាការចូលរួមចំណែកក្នុងសង្គម និងកំណើនសេដ្ឋកិច្ចផងដែរ។

## ៤-ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

ធនាគារមិនមានធាតុ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលខុសពីធម្មតាជាសារវន្តនោះទេ។ ទោះជាយ៉ាងណាក៏ដោយលក្ខខណ្ឌសេដ្ឋកិច្ចដែលបានរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ អាចជះឥទ្ធិពលដល់សមត្ថភាពសងត្រលប់មកវិញរបស់អតិថិជន ដែលគុណភាពឥណទានរបស់ធនាគារអាចរងផលប៉ះពាល់បន្តិចបន្តួច។

## គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ដើម្បីចូលរួមគាំទ្រការរីកលូតលាស់អាជីវកម្មរបស់អតិថិជន ធនាគារ អេស៊ីលីដា ភីអិលស៊ី បានបញ្ចុះអត្រាការប្រាក់ពី 0,៤% រហូតដល់ ១% ក្នុង ១ឆ្នាំ បន្ថែមទៀតលើការស្នើសុំឥណទានថ្មីគ្រប់ប្រភេទ និងដោយកាន់តែមានភាពងាយស្រួល អតិថិជនទាំង

អស់អាចដាក់សំណើសុំឥណទានតាមរយៈ **អេស៊ីលីដាម៉ូបាល**។ ជាលទ្ធផល សមតុល្យឥណទានដុលសរុបនៅត្រីមាសទី៤ ឆ្នាំ ២០២០ មានការកើនឡើងចំនួន ១,២៤ ទ្រីលានរៀល ស្មើនឹង ៧,២៩% ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២០។

## ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបានប្រែប្រួលនៅគន្លងខ្ពស់បន្តិចក្នុងចន្លោះ ៤.០៥០ រៀលទៅ ៤.១១០ រៀល ក្នុងមួយដុល្លារអាមេរិក ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២០។ នៅដើមឆ្នាំ២០២១ តម្លៃប្រាក់រៀលបានរក្សាស្ថិរភាពនៅត្រឹម ៤.០៦៥ រៀលក្នុងមួយដុល្លារអាមេរិក និងរំពឹងថានឹងរក្សាស្ថិរភាពប្រហាក់ប្រហែលនេះនៅក្នុងឆ្នាំ២០២១។ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានអនុវត្តយ៉ាងម៉ឺងម៉ាត់តាមតម្រូវការនៃបទប្បញ្ញត្តិ និងគោលការណ៍ផ្ទៃក្នុងធនាគារ ទាក់ទងទៅនឹងស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណ។ ដោយហេតុនេះមានផលប៉ះពាល់តិចតួចប៉ុណ្ណោះដែលបណ្តាលមកពីការឡើងចុះនៃអត្រាប្តូរប្រាក់ ហើយផលប៉ះពាល់នោះត្រូវបានវាស់វែង តាមដាន និងគ្រប់គ្រងជារៀងរាល់ថ្ងៃដើម្បីចាត់វិធានការដោះស្រាយភ្លាមៗ។

អត្រាការប្រាក់ជាមធ្យមនៃប្រាក់បញ្ញើមានកាលកំណត់ និងប្រាក់កម្ចីបានថយចុះបន្តិចពីដើមឆ្នាំ ដល់ខែសីហា ឆ្នាំ២០២០ ពី ៣,៧០% ទៅ ៣,៤៧% និងពី ៩,៥៥% ទៅ ៩,២៧% រៀងគ្នា (យោងព័ត៌មានស្ថិតិសេដ្ឋកិច្ច និងរូបិយវត្ថុខែសីហា ២០២០ របស់ធនាគារជាតិ នៃ កម្ពុជា)។ បម្រែបម្រួលទាំងនេះស្ថិតនៅក្នុងស្ថានភាពធម្មតានៃអាជីវកម្ម ហើយមានផលប៉ះពាល់តិចតួចបំផុតដល់ធនាគារ។ ម្យ៉ាងវិញទៀត ធនាគារបានធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួនដោយផ្អែកលើអត្រាការប្រាក់ថេរ (ទាំងប្រាក់បញ្ញើនិងប្រាក់កម្ចី) ដែលមិនមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងចលនាអត្រាការប្រាក់នៅក្នុងទីផ្សារហិរញ្ញវត្ថុអន្តរជាតិឡើយ។ លើសពីនេះទៀត ហានិភ័យអត្រាការប្រាក់ត្រូវបានវាស់វែង តាមដាន និងគ្រប់គ្រងជាប្រចាំ ដើម្បីជៀសវាងផលប៉ះពាល់ផ្សេងៗចំពោះលទ្ធផលការងាររបស់ធនាគារ។

ធនាគារមិនបានធ្វើប្រតិបត្តិការជួញដូរដែលមានទម្រង់ជា commodity នោះទេ។

## ង-ផលប៉ះពាល់នៃអតិផរណា

ដូចការរំពឹងទុក ការរក្សាអត្រាអតិផរណារបស់រាជរដ្ឋាភិបាលសម្រាប់ឆ្នាំ២០២០ គឺនៅកម្រិតទាប ជាមធ្យម ២,៩% ទោះស្ថិតក្នុងអំឡុងពេលផ្ទុះឡើងនៃជំងឺកូវីដ-១៩ ក៏ដោយ។ ដោយហេតុនេះ វាមានផលប៉ះពាល់តិចតួចបំផុតពីអតិផរណាលើអាជីវកម្មរបស់ធនាគារ។ អតិផរណាត្រូវបានព្យាករថាស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន គឺប្រហែល ៣% នៅឆ្នាំ២០២១។

## ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល

- **គោលនយោបាយសេដ្ឋកិច្ច៖**

កំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២០ ត្រូវបានប៉ាន់ស្មានថាអាចធ្លាក់ចុះជាងការរំពឹងទុកកាលពីដើមឆ្នាំ ដែលថាអត្រាកំណើនអាចមានកម្រិត -៣,១%។ ការធ្លាក់ចុះជាងការរំពឹងទុកនេះ ជាចម្បងដោយសារវិស័យទេសចរណ៍មិនមានភាពប្រសើរឡើង ដោយបន្តធ្លាក់ចុះខ្លាំងនៅក្នុងឆមាសទី២ ស្របពេលដែលការនាំចេញក្នុងវិស័យកាត់ដេរ ដែលរួមចំណែករហូតដល់ ៧០%នៃការនាំចេញសរុបបន្តមាននិន្នាការធ្លាក់ចុះ។ អត្រាអតិផរណាសម្រាប់ឆ្នាំ២០២០ មានកម្រិតជាមធ្យម ២,៩% ខ្ពស់ជាងឆ្នាំមុនបន្តិច (១,៩%) និងអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកបន្តមានស្ថិរភាព ដោយមានកម្រិតជាមធ្យមក្នុងរង្វង់ ៤.០៩០ រៀលក្នុង ១ដុល្លារអាមេរិក ខ្ពស់ជាងឆ្នាំមុន (៤.០៦១ រៀល)។

ក្នុងបរិការណ៍ដែលថ្នាំបង្ការមានប្រសិទ្ធភាពអាចទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងឆមាសដំបូងនៃឆ្នាំ២០២១ ធនាគារជាតិ នៃ កម្ពុជា បានព្យាករថា សេដ្ឋកិច្ចកម្ពុជាអាចនឹងងើបឡើងវិញក្នុងរង្វង់ ៣,៥% ហើយអត្រាអតិផរណារំពឹងថាមានកម្រិតគ្រប់គ្រងបានក្រោម ៣% ជាមួយនឹងស្ថិរភាពអត្រាប្តូរប្រាក់ និងការរក្សាបានកម្រិតខ្ពស់នៃទុនបម្រុងអន្តរជាតិ។ ចំណែកឯស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានាបានព្យាករថា អត្រាកំណើនសេដ្ឋកិច្ចកម្ពុជាអាចសម្រេចបានពី ៤% ទៅ ៦,៨% អាស្រ័យលើប្រសិទ្ធភាពនៃថ្នាំបង្ការ ល្បឿននៃការងើបឡើងវិញនៃកំណើនក្នុងប្រទេសជាដៃគូសេដ្ឋកិច្ច និងការពង្រឹងមូលដ្ឋានសេដ្ឋកិច្ចក្នុងស្រុក។

ស្ថិតក្នុងបរិការណ៍នេះ ការបន្តពង្រឹងសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកថែមទៀតនឹងជួយទ្រទ្រង់ និងកាត់បន្ថយការប៉ះពាល់លើកំណើនសេដ្ឋកិច្ចកម្ពុជា ដោយសារការធ្លាក់ចុះវិស័យខាងក្រៅ។ ដូច្នេះ ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការលើកស្ទួយការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ការជំរុញនវានុវត្តន៍ និងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗលើគ្រប់វិស័យ មានសារៈសំខាន់ណាស់

ក្នុងការពង្រឹងមូលដ្ឋានកំណើនសកម្មភាពក្នុងស្រុក។ ជាមួយគ្នានេះ វិស័យកសិកម្មនឹងបន្តជាវិស័យដ៏សំខាន់ និងមានសក្តានុពលខ្ពស់ ដែលអាចជួយស្រូបឥទ្ធិពលផ្នែកខ្លះនៃវិបត្តិ ដូចជាភាពអត់ការងារធ្វើ ឬជួយគាំទ្រជីវភាពប្រជាជនក្រីក្រ។ ម៉្យាងទៀត ការពន្លឿនការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច និងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឧស្សាហកម្ម នឹងជួយឲ្យសេដ្ឋកិច្ចកម្ពុជាងើបឡើងកាន់តែឆាប់រហ័សពីវិបត្តិនាបច្ចុប្បន្ននេះ។ លើសពីនេះ ការចាប់ផ្តើមទទួលបានចំណូលពីការផលិតប្រេងនៅកម្ពុជា នឹងផ្តល់ជាប្រភពថវិកាមួយទៀត សម្រាប់ការអភិវឌ្ឍវិស័យអាទិភាពនានានៅពេលខាងមុខ។ (១)(២)

- **គោលនយោបាយសារពើពន្ធ៖**

តាមរយៈអគ្គនាយកដ្ឋានពន្ធដារឲ្យដឹងថា សរុបរយៈពេល ១២ខែ ឆ្នាំ២០២០ ចំណូលពន្ធ-អាករ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន (តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ) មានចំនួន ១១.៧០០,៥២ ប៊ីលានរៀល (ប្រមាណជា ២.៨៨៩,០២ លានដុល្លារអាមេរិក) ស្មើនឹង ១០១,៣៦% នៃផែនការប្រចាំឆ្នាំ ធៀបនឹងចំណូលពន្ធ-អាករប្រមូលបានក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩ ឃើញថាកើនឡើងចំនួន ៤២៣,២០ ប៊ីលានរៀល (ប្រមាណជា ១០៤,៤៩ លានដុល្លារអាមេរិក) ស្មើនឹង ៣,៧៣% ទោះក្នុងស្ថានភាពសេដ្ឋកិច្ចសកល ក៏ដូចជាសេដ្ឋកិច្ចកម្ពុជា មិនទាន់មានភាពប្រាកដប្រជា ជាពិសេសមានការទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីការរីករាលដាលនៃជំងឺកូវីដ-១៩។ ចំពោះលទ្ធផលក្នុងខែធ្នូ ឆ្នាំ២០២០ បានបង្ហាញថាចំណូលពន្ធ-អាករគ្រប់ប្រភេទដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន មានចំនួន ៩៧២,២៧ ប៊ីលានរៀល ស្មើប្រមាណជា ២៤០,០៧ លានដុល្លារអាមេរិក ស្មើនឹង ៨,៤២% នៃផែនការប្រចាំឆ្នាំ បើធៀបនឹងចំណូលពន្ធអាករប្រចាំខែធ្នូ ឆ្នាំ២០១៩ ឃើញថាកើនឡើងចំនួន ១៩២,១១ ប៊ីលានរៀល ស្មើប្រមាណជា ៤៧,៤៣ លានដុល្លារអាមេរិក ឬស្មើនឹង ២៤,៦២%។

សម្រាប់ឆ្នាំ២០២១ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានគាំទ្រលើវិធានការដែលបានដាក់ចេញរបស់អគ្គនាយកដ្ឋានពន្ធដារ និងបានផ្តល់អនុសាសន៍សំខាន់ៗ ជាទិសដៅអនុវត្តបន្តដូចជា៖ (១) ត្រូវយកចិត្តទុកដាក់ពិនិត្យ និងសិក្សាលើលទ្ធភាពនៃការប្រមូលចំណូលដែលមានសក្តានុពលផ្សេងទៀត ដោយគិតគូរទាំងទិដ្ឋភាពចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ដើម្បីធានាបាននូវអនុលោមភាពសារពើពន្ធ និងការប្រមូលចំណូលឱ្យបានគ្រប់ជ្រុងជ្រោយ ក្នុងនោះប្រភពចំណូលពីវិស័យ E-Commerce វិស័យប្រេងកាតដែលជាសក្តានុពលថ្មី វិស័យធនធានរ៉ែ ព្រមទាំងវិស័យដែលមានសក្តានុពលមួយចំនួនទៀត។ (២) រៀបចំកែសម្រួលបទប្បញ្ញត្តិក្នុងការកំណត់និយមន័យសហគ្រាសធុនតូច និងមធ្យម និងជំរុញសម្រួលលើកកម្ពស់សហគ្រាសធុនតូច និងមធ្យមមកក្នុងប្រព័ន្ធ ក្នុងគោលដៅជំរុញកំណើន និងបង្កើតជាកាលានុវត្តភាពសេដ្ឋកិច្ច។ (៣) ពង្រឹងការចុះបញ្ជីពន្ធដារ និងជំរុញការបំពេញកាតព្វកិច្ចសារពើពន្ធសម្រាប់សហគ្រាសក្នុងវិស័យកាស៊ីណូ ដើម្បីធានាឱ្យបាននូវតម្លាភាពសារពើពន្ធ និងការគ្រប់គ្រងប្រមូលចំណូលពន្ធឱ្យបានជាអតិបរមា។ (៤) បន្តអនុវត្តកំណែទម្រង់ស្ថាប័ន ទំនើបកម្មរដ្ឋបាលសារពើពន្ធ-ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយធានាយ៉ាងណាបង្កភាពងាយស្រួល (User Friendly) សម្រាប់អ្នកជាប់ពន្ធនិងមន្ត្រី ព្រមទាំងពង្រឹងអនុលោមភាពសារពើពន្ធ ដើម្បីជំរុញប្រសិទ្ធភាព និងភាពប្រទាក់ក្រឡាក្នុងការបំពេញបេសកកម្មគ្រប់គ្រងប្រមូលចំណូលពន្ធ។ (៥) បន្តអនុវត្តប្រកបដោយការយកចិត្តទុកដាក់នូវយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល។ (៦) បន្តពង្រឹងការអនុវត្តឱ្យមានប្រសិទ្ធភាពនូវការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (IT Platform) ស្របតាមខ្លឹមសារអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០។ (៧) ពង្រឹង និងយកចិត្តទុកដាក់លើការធ្វើសវនកម្ម ស្របតាមខ្លឹមសារប្រកាសលេខ ២៧០ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ ស្តីពីសវនកម្មពន្ធដារ ដែលជាជញ្ជីងវាស់នូវអនុលោមភាពរបស់សហគ្រាស និងចៀសវាងការបង្កការលំបាកដល់អ្នកជាប់ពន្ធ។ (៨) បន្តលើកកម្ពស់ និងបញ្ជ្រាបវប្បធម៌បង់ពន្ធ ពង្រឹងការផ្សព្វផ្សាយ និងអនុវត្តបទប្បញ្ញត្តិថ្មីៗពាក់ព័ន្ធនឹងពន្ធដារជូនដល់មន្ត្រីអនុវត្តផ្ទាល់ អ្នកជាប់ពន្ធ និងសាធារណជន ដើម្បីពន្យល់និងដោះស្រាយការលំបាក និងចម្ងល់របស់ប្រជាពលរដ្ឋ។ (៩) បន្តកិច្ចសហការ និងពិគ្រោះយោបល់ជាមួយវិស័យពាក់ព័ន្ធ ដើម្បីទទួលយកធាតុចូលក្នុងការសិក្សា រៀបចំ និងកែលម្អបទប្បញ្ញត្តិពាក់ព័ន្ធចាំបាច់នានា។ (3)(4)(5)

- **គោលនយោបាយរូបិយវត្ថុ៖**

គិតមកត្រឹមត្រីមាសទី៤ ឆ្នាំ២០២០ រូបិយវត្ថុទូទៅ M2 បានកើនឡើង ១៤,៧% ទាបជាងកំណើនឆ្នាំមុន (១៨,២%) ដែលបណ្តាលមកពីកំណើនទាបជាងមុននៃរូបិយវត្ថុក្នុងចរាចរណ៍ និងប្រាក់បញ្ញើសរុបរបស់និវាសជនទាំងប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក ដោយសារតែការផ្អាកធ្វើអន្តរាគមន៍ទិញប្រាក់ដុល្លារអាមេរិកចាប់ពីខែឧសភា ឆ្នាំ២០២០ មក គួបផ្សំនឹងការឆ្លើយតបនឹងតម្រូវការ

ខ្ពស់លើប្រាក់រៀលក្នុងឆ្នាំ២០១៩។ ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ ធនាគារជាតិ នៃ កម្ពុជាបានបង្កើនកម្រិតសន្ទនីយភាពក្នុងប្រព័ន្ធធនាគារ និងបានពង្រឹងជំនឿទុកចិត្តមកលើវិស័យធនាគារ និងប្រាក់រៀល ដោយបានលក់ប្រាក់ដុល្លារអាមេរិក ៨០,២ លានដុល្លារអាមេរិក (៤លើក) ទៅគ្រឹះស្ថានហិរញ្ញវត្ថុ និងអាជីវករប្តូរប្រាក់ និងបានលក់ប្រាក់រៀល ឆ្លើយតបនឹងតម្រូវការចំនួន ៦៩,៥ ប៊ីលានរៀល (១៧ លានដុល្លារអាមេរិក)។ ទន្ទឹមនឹងនោះ ធនាគារជាតិ បានលក់ប្រាក់ដុល្លារអាមេរិកសុទ្ធចំនួន ១៤៧,១ លានដុល្លារអាមេរិក ទៅស្ថាប័នរដ្ឋ។ ធនាគារជាតិ នៃ កម្ពុជាបានទម្លាក់អត្រាប្រាក់បម្រុងកាតព្វកិច្ចជារៀល និងជាដុល្លារអាមេរិកមកត្រឹម ៧% ចាប់ពីខែមេសា ឆ្នាំ២០២០ ពីកម្រិត ៨% ចំពោះប្រាក់បញ្ញើជាប្រាក់រៀល និង១២,៥% ចំពោះរូបិយប័ណ្ណបរទេស។ ការចេញផ្សាយ NCD ចារឹកជាដុល្លារអាមេរិកមានចំនួន ៣០,៨ ប៊ីលានដុល្លារអាមេរិក ដែលបានកើនឡើង ៤៥,៣% ធៀបនឹងឆ្នាំមុន ដោយសារគ្រឹះស្ថានធនាគារមានសន្ទនីយភាពខ្ពស់។ ចំណែកឯការចេញផ្សាយ NCD ចារឹកជារៀលមាន ១០,៩ ទ្រីលានរៀល ដោយបានកើនឡើង ៤% ប៉ុណ្ណោះ។ រីឯអត្រាការប្រាក់ NCD ក៏ត្រូវបានកាត់បន្ថយក្នុងកម្រិតសមស្រប។ ចំណែកឯប្រតិបត្តិការ LPCO ត្រូវបានធ្វើឡើងចំនួន ២៣ លើក ដែលបានផ្តល់សន្ទនីយភាពជាប្រាក់រៀលសរុប ៥,៩ ទ្រីលានរៀល ដោយបានកើនឡើង ២៤,៥% ធៀបនឹងឆ្នាំមុន ជាមួយនឹងអត្រាការប្រាក់ដេញថ្លៃឈ្នះជាមធ្យម ៣,០៣% សម្រាប់តណាប្រតិទាន ៣ខែ ៣,៤៤% សម្រាប់តណាប្រតិទាន៦ខែ ៣,៧៧% សម្រាប់តណាប្រតិទាន១ឆ្នាំ។ ទំហំ LPCO ដែលមិនទាន់ដល់តណាប្រតិទានមាន ៣,៩ ទ្រីលានរៀល គិតត្រឹមចុងខែធ្នូ ឆ្នាំ២០២០។ គួររំលេចថា អត្រាការប្រាក់ដេញថ្លៃអប្បបរមា LPCO ត្រូវបានកាត់បន្ថយ ០,៥% សម្រាប់គ្រប់តណាប្រតិទានទាំងអស់។ គោលនយោបាយនេះ ដកស្រង់ចេញពីរបាយការណ៍ប្រចាំឆ្នាំ២០២០ របស់ធនាគារជាតិ នៃ កម្ពុជា។

សម្រាប់ឆ្នាំ២០២១ ធនាគារជាតិ នៃ កម្ពុជា បានកំណត់អនុវត្តគោលនយោបាយរូបិយវត្ថុចំនួន៤ រួមមាន៖ (១) ការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឲ្យស្ថិតក្នុងកម្រិតសមស្រប (២) រក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដើម្បីរួមចំណែកស្ថិរភាពថ្លៃ និងជំនឿទុកចិត្តរបស់សាធារណជន (៣) លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលតាមយន្តការទីផ្សារ និង (៤) ជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារតាមរយៈការបង្កើនឧបករណ៍គោលនយោបាយរូបិយវត្ថុចាំបាច់ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ។ [១]

**ឯកសារយោង:**


(1) https://www.nbc.org.kh/download_files/publication/annual_rep_kh/Ann_Report_2020_KHR.pdf
(2) https://www.nbc.org.kh/download_files/other_reports/khmer/Macroeconomic_2020_and_outlook_2021.pdf
(3) https://dap-business.com/finance/2021/01/13/4567/
(4) https://www.kampucheathmey.com/business-economic/45563/
(5) https://cambojanews.com/tax-collections-rise-in-2020-despite-covid-19-pandemic/


**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ**

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១

បានអាន និងឯកភាព

ហត្ថលេខា

**ឆាយ សឿន**

**ប្រធានក្រុមប្រឹក្សាភិបាល**

ការិយាល័យកណ្តាល ៖ អគារលេខ៦១ មហាវិថីព្រះមុនីវង្ស
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩ | ទូរសារ ៖ ០២៣ ៤៣០ ៥៥៥
acledabank@acledabank.com.kh | www.acledabank.com.kh
ប្រអប់សំបុត្រលេខ ៖ ១១៤៩ | SWIFT Code ៖ ACLBKHPP

ការិយាល័យទំនាក់ទំនងអតិថិជន (បម្រើ ២៤ម៉ោង)
ទូរស័ព្ទ ៖ ០២៣ ៩៩៤ ៤៤៤, ០១៥ ៩៩៩ ២៣៣
inquiry@acledabank.com.kh